# គំនិតសម្រាប់មុខងារនៅសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ឆាក់ឆងនឹងជន រងគ្រោះ

*បណ្ឌិត Marie Wilmet អ្នកស្រាវជ្រាវច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅវិទ្យាស្ថានសាកលវិទ្យាល័យអឺរ៉ុប អ្នកសហការស្រាវជ្រាវនៅមជ្ឈមណ្ឌល Thucydide សាកលវិទ្យាល័យប៉ារីស II អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលសិក្សាខ្មែរ។*

ការចូលរួមនេះបានទាញចេញពីការសម្ភាសន៍ចំនួន៣០ ដែលបានធ្វើឡើងជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានចូលរួមនៅក្នុងសំណុំរឿង ០០២/០២ ដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្ម ដែលពួកគេបានទទួលរង ជាលទ្ធផលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការសម្ភាសន៍ចំនួន ១៨ ជាមួយមន្ត្រីច្បាប់ដែលធ្លាប់ធ្វើការ ឬកំពុងធ្វើការនៅ អ.វ.ត.ក និងជាមួយ អ.វ.ត.ក ព្រមទាំងការពិភាក្សាក្រៅផ្លូវការជាច្រើន ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។ ការសម្ភាសន៍បានបង្ហាញ ពីផ្នែកចំនួនបួននៃការអនុវត្ត ដែលអាចមានអត្ថន័យសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះនៃរបបខ្មែរក្រហម និងសម្រាប់មនុស្សជំនាន់ក្រោយ។

១. <u>សេវាសុខភាពផ្លូវកាយនិងផ្លូវចិត្ត</u>

ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួម ក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ជាមធ្យមគឺស្ថិតក្នុងស្ថានភាពលំបាកខ្លាំងផ្នែកហិរញ្ញវត្ថុ ហើយពួកគាត់ឈានដល់វ័យចំណាស់។ ដោយសារផលវិបាកនៃឧក្រិដ្ឋកម្ម ដើមបណ្ដឹងរដ្ឋប្បវេណី បានទទួលរងការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ។ នាពេលនេះការឈឺចាប់មួយចំនួនបានលេចចេញជាជំងឺផ្សេងៗគ្នា ដែលទាមទារឲ្យមានការព្យាបាល ដែលដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ មិនមានលទ្ធភាពព្យាបាល។ ដើម្បីផ្ដល់ជាឧទាហរណ៍ជាក់ស្ដែង ដើមបណ្ដឹងរដ្ឋប្បវេណីខ្លះដែលយើងសម្ភាសន៍ចាំបាច់ត្រូវចំណាយលុយសម្រាប់ថ្នាំពេទ្យ ដើម្បីជួយដល់បញ្ហាសុខភាពផ្លូវចិត្តរបស់ពួកគាត់។ ការព្យាបាលរយៈពេលបីខែត្រូវចំណាយប្រមាណ១០០ដុល្លា គឺជាបន្ទុកហិរញ្ញវត្ថុ ដែលខ្ពស់ខ្លាំងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្អែកលើស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ពួកគាត់។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏ទទួលរងការឈឺចាប់ បណ្ដាលមកពីស្ថានភាពផ្លូវកាយដែលចុះទ្រុឌទ្រោម ដោយសារតែអំពើឧក្រិដ្ឋដែលប្រព្រឹត្តទៅលើពួកគាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែការចូលព្យាបាលនៅមន្ទីរពេទ្យ គឺហួសពីសមត្ថភាពរបស់ពួក

គាត់។ បើទោះបីជាចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមក្តី តែវាហាក់ដូចជាបង្ហាញថា ជនរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រនិងផ្លូវភេទ ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម បានធ្វើឲ្យសុខភាពបន្តពូជ និងសុខភាពផ្លូវភេទរបស់ពួកគាត់ ទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ដែលបង្កើតជាបន្ទុកហិរញ្ញវត្ថុបន្ថែមទៀត សម្រាប់ពួកគាត់នាពេលបច្ចុប្បន្ន[1]។

ហេតុដូច្នេះ មុខងារនៅសេសសល់របស់ អ.វ.ត.ក អាចព្យាយាមផ្តល់ជំនួយខ្លះៗដល់បញ្ហាសុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ការនេះអាចអនុវត្តបានតាមការបន្ត និងពង្រីកគម្រោងសំណងទី១៣ ដែលបានផ្តល់ជូនក្នុងសំណុំរឿង ០០២/០២ គឺបន្ទប់ព្យាបាលចល័ត ដែលដំណើរការនៅបណ្តាខេត្តជាច្រើនក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់ជូនទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ ជាជម្រើសមួយទៀត ដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលបាន ប័ណ្ណធានារ៉ាប់រងសុខភាព ដើម្បីចំណាយសម្រាប់បញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគាត់។ ការនេះប្រហែលជាអាចសម្រេចទៅបាន តាមការសហការណ៍ជាមួយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈកម្មវិធីប័ណ្ណសមធម៌។ មុនពេលអនុវត្តគំនិតណាមួយ គឺជាការចាំបាច់ដែលត្រូវធ្វើការស្ទង់មតិ ឬការស្រាវជ្រាវ ដើម្បីវាយតម្លៃលើចំនួន ដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅមានជីវិត។ តាមពិតទៅ ជាមួយក្រុមស្រាវជ្រាវ យើងបានចូលទៅដល់ភូមិចំនួន ១១ នៅតាមបណ្តាខេត្តចំនួន ៦ ដើម្បីទៅជួបដើមបណ្តឹងរដ្ឋប្បវេណី នៃការរៀបការដោយបង្ខំ។ នៅពេលទៅដល់ភូមិ ពួកយើងទទួលបានព័ត៌មានថា (ជាមធ្យម) ដើមបណ្តឹងរដ្ឋប្បវេណីពាក់កណ្តាល បានស្លាប់ឬធ្លាក់ខ្លួនឈឺធ្ងន់រួចទៅហើយ។

## ២. ព័ត៌មានអំពី អ.វ.ត.ក កិច្ចដំណើរការនីតិវិធី និងសំណងរបស់ អ.វ.ត.ក

ការសម្ភាសន៍បង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណី មិនបានទទួលព័ត៌មានអំពី អ.វ.ត.ក ឬមេធាវីរបស់ពួកគេតាំងពីឆ្នាំ២០១៧ ឬ២០១៨ មកម្ល៉េះ។ ទោះបីជាពួកគាត់បង្ហាញភាពវិជ្ជមានជាទូទៅ អំពីការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី របស់ពួកគាត់ក្តី តែពួកគាត់មួយចំនួន បង្ហាញពីអារម្មណ៍មិនពេញចិត្ត ដោយសារតែមិន

---

[1] ការនេះធ្លាប់ត្រូវបានលើកឡើង នៅក្នុងការសម្ភាសន៍ជាមួយអ្នកជំនាញ ដែលធ្វើការលើការស្រាវជ្រាវជាច្រើន ជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៃអំពើហិង្សាលើយេនឌ័រ និងផ្លូវភេទ ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម។ អ្នកជំនាញបានលើកឡើងថា ទោះបីថាដូចជាមិនមានការប្រមូលទិន្នន័យលើបញ្ហានេះក្តី តែការស្រាវជ្រាវរបស់គាត់បានបង្ហាញថា អាចមានអត្រាខ្ពស់នៃការចម្លងជំងឺកាមរោគ ទៅលើជនរងគ្រោះទាំងនោះ។

មានព័ត៌មាន និងការផ្ដល់ព័ត៌មានបន្ថែម នៅក្នុងបណ្ដាឆ្នាំកន្លងមកថ្មីៗ។ ភាពច្រើននៃពួកគាត់មិនបានដឹង អំពីស្ថានភាពនៃសំណុំរឿងរបស់ខ្លួន (សំណុំរឿង ០០២/០២) ហើយពួកគាត់មានមន្ទិលថាតើ អ.វ.ត.ក បានបិទទ្វារហើយឬនៅ។ លើសពីនេះទៀត ពួកគាត់ភាគច្រើនមិនបានដឹង អំពីកម្មវិធីសំណង[2]។ ជាបញ្ហានោះ ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដែលត្រូវបានប្រឹក្សាអំពីការចង់បានរបស់ពួកគាត់ ទាក់ទងនឹងសំណង តែមិនដែលទទួលបានព័ត៌មាន អំពីគម្រោងដែលត្រូវបានអនុម័តយល់ព្រម ដោយអង្គជំនុំជម្រះសាលាដំបូង។ ការផ្ដល់ព័ត៌មានបែបនេះដល់ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាការចាំបាច់ ជាពិសេសដោយសារតែគម្រោងជាច្រើន គឺបើកទូលាយដោយសេរី (ដូចជាកម្មវិធីប្រវត្តិសាស្ត្រខ្មែរក្រហម ឬខ្សែវីដេអូនៃគម្រោងផ្កាស្លាក្រោមអង្គការ)។ វិធានការដែលអាចអនុវត្តបាន សម្រាប់មុខងារនៅសេសសល់ គឺរៀបចំជាវគ្គឬសិក្ខាសាលាផ្ដល់ព័ត៌មាន នៅតាមខេត្ត ដែលក្នុងពេលនោះគម្រោងដែលងាយទទួលបាន អាចត្រូវបានលើកយកមកបង្ហាញ[3]។ កម្មវិធីនេះអាចចូលរួមបានទាំងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាសាធារណជនទូទៅ ដែលនឹងជួយបង្កើនចំណេះដឹងអំពី អ.វ.ត.ក នៅក្នុងប្រទេសកម្ពុជា។

៣. <u>ចេតិយនិងពិធីបែបពុទ្ធសាសនា</u>

ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញពីបំណងរបស់ពួកគាត់ ចង់ឲ្យមានការសង់ចេតិយ នៅតាមវត្ត ដែលនៅក្បែរផ្ទះរបស់ពួកគាត់ ដើម្បីគោរពដល់សាច់ញាតិជិតស្និទ្ធរបស់ពួកគាត់ ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។ នៅពេលសាកសួរថាសំណងអ្វីដែលពួកគាត់ចង់បានពីដំបូង ពីតុលាការនោះ ចេតិយគឺជាជម្រើសទីមួយឬទីពីរនៃសំណងដែលពួកគាត់បានលើកឡើង (ជម្រើសមួយទៀតគឺសំណងហិរញ្ញវត្ថុ)។ ដោយសារតែភាពសំខាន់នៃពុទ្ធសាសនានៅក្នុងសង្គមកម្ពុជា ការកសាងចេតិយគឺមានអត្ថន័យខ្លាំងបំផុត សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាជនរងគ្រោះដទៃទៀតនៃរបបខ្មែរក្រហម និងក្រុមគ្រួសាររបស់ពួកគាត់ (រួមទាំងក្មេងជំនាន់ក្រោយផង)។ បន្ថែមលើនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលចូលរួមក្នុង គម្រោងសំណងរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ ពាក់ព័ន្ធពិធីបែបពុទ្ធសាសនា នៅវត្តទួលទំពូង សុទ្ធតែបានបង្ហាញថា ចេតិយគឺសំខាន់ណាស់

---

[2] ក្នុងករណីខ្លះ ដើមបណ្ដឹងរដ្ឋប្បវេណីបានចូលរួមក្នុងគម្រោង ដែលអង្គជំនុំជម្រះសាលាដំបូងបានអនុម័ត ប៉ុន្តែមិនបានដឹងថាកម្មវិធីទាំងអស់នោះ គឺជាសំណងឡើយ។

[3] ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលបានសម្ភាសន៍ បានចែករំលែកអំពីបំណងប្រាថ្នារបស់ពួកគាត់ ដែលចង់ឲ្យមន្ត្រីតុលាការ ចុះមកដល់ខេត្ត មិនត្រឹមតែឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ទៅទីក្រុងភ្នំពេញប៉ុណ្ណោះទេ។

សម្រាប់ពួកគាត់។ ដោយមានជំនួយពីព្រះសង្ឃ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា ពួកគាត់អាចជួយដល់មនុស្សជាទីស្រឡាញ់របស់ពួកគាត់ ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយមិនមានពិធីបុណ្យសព។ ហេតុដូច្នេះជាការសំខាន់ ក្នុងការពង្រីកគម្រោងរបស់ អង្គការចិត្តសង្គម អន្តរវប្បធម៌ ដើម្បីឲ្យទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះកាន់តែច្រើន។ កម្មវិធីនេះនឹងកាន់តែមានន័យ ប្រសិនបើធ្វើឡើងនៅតាមបណ្ដាខេត្តជាច្រើន រួមទាំងទីតាំងដែលនៅឆ្ងាយពីរាជធានីភ្នំពេញ។

៤. <u>ការរក្សាឯកសារ និងការផ្សព្វផ្សាយចំណេះដឹង អំពីរបបខ្មែរក្រហម</u>

ដើមបណ្ដឹងរដ្ឋប្បវេណីសឹងតែទាំងអស់ ដែលត្រូវបានសម្ភាសន៍ ទទួចអំពីសារសំខាន់ នៃការថែរក្សាចំណេះដឹង និងភស្តុតាងដែលប្រមូលបាន ក្នុងរបបខ្មែរក្រហម។ ការព្រួយបារម្ភធំមួយរបស់ពួកគាត់គឺថា គ្មាននរណាម្នាក់នៅចងចាំអំពីអ្វី ដែលបានកើតឡើង ក្រោយពីពួកគាត់បានស្លាប់ទៅ។ ការអនុវត្តជាច្រើនអាចឆ្លើយតប ចំពោះក្ដីបារម្ភនេះ។ ទីមួយ បង្កើតជាប្រធាននៅសាកលវិទ្យាល័យធំមយយរបស់កម្ពុជា ដើម្បីធ្វើការស្រាវជ្រាវពីផ្នែកអន្តរជំនាញ ស្ដីពីរបបខ្មែរក្រហម ដែលគេយល់ដឹងជាទូលំទូលាយ។ ជាការចាំបាច់ក្នុងការបង្កើតតំណែងបណ្ឌិត ដើម្បីជម្រុញឲ្យមានការស្រាវជ្រាវ និងអប់រំអំពីបញ្ហាទាំងអស់នេះ[4]។ ទីពីរបណ្ណាសាររបស់ អ.វ.ត.ក និងជាពិសេសភស្តុតាងយ៉ាងច្រើនដែលប្រមូលបាន ក្នុងពេលស៊ើបអង្កេត អាចត្រូវបានលើកកម្ពស់និងបញ្ចាក់បង្ហាញ តាមរយៈកិច្ចសហការជាមួយគម្រោងកត់ត្រាការចងចាំនៅកម្ពុជា។ គម្រោងនេះក៏នឹងលើកកម្ពស់ផងដែរ ដល់កិច្ចពិភាក្សាច្រើនជំនាន់ ដោយសារតែគម្រោងនេះពាក់ព័ន្ធ ជាមួយការចូលរួមរបស់និសិត្សនៅតាមសាកលវិទ្យាល័យនៅកម្ពុជា។ ទីបីនិងចុងក្រោយគឺបណ្ណាសារផ្ទាល់មាត់អំពី អ.វ.ត.ក ដែលអាចប្រមូលបានដើម្បីបន្តរក្សាប្រវត្តិសាស្ត្រ អ.វ.ត.ក ឲ្យនៅរស់រានបន្ត។ ក្រុមការងារមួយអាចធ្វើការសម្ភាសន៍ ជាមួយមន្ត្រីដែលធ្លាប់ធ្វើការនៅតុលាការ ព្រមទាំងជាមួយដើមបណ្ដឹងរដ្ឋប្បវេណី អំពីបទពិសោធន៍របស់ពួកគាត់ ស្ដីពីកិច្ចដំណើរការនីតិវិធីតុលាការ។ ការនេះក៏នឹងឆ្លើយតបផងដែរចំពោះតម្រូវការ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលចង់ឲ្យកត់ត្រារឿងរ៉ាវរបស់ពួកគាត់ ដើម្បីប្រាប់ដល់ក្មេងជំនាន់ក្រោយ។ គំនិតនេះត្រូវបានបង្កើតរួមគ្នា

---

[4] ទោះបីជាមានអ្នកស្រាវជ្រាវកម្ពុជាល្អៗជាច្រើនក្នុងពេលបច្ចុប្បន្ន ដែលបានធ្វើការអំពីខ្មែរក្រហម និង អ.វ.ត.ក ក្ដី តែពួកគាត់មិនមានឱកាសស្រាវជ្រាវយកសញ្ញាបត្របណ្ឌិត នៅក្នុងប្រទេសកម្ពុជា។

ជាមួយលោក Vincent Lansalot បណ្ណាសាររក្សនៅបណ្ណាសារដ្ឋានជាតិបារាំង និងជាប្រធានគ្រប់គ្រងគម្រោង នៃផ្នែកបណ្ណាសារឧក្រិដ្ឋកម្មសង្គ្រាមលោកលើកទីពីរ។